| | | |
|---|---|---|
| Name of Media | : | Phnom Penh Post, Cambodia |
| Date of Article | : | 1 July 2007 |
| Author | : | Rith sam |
| Pages | : | 1/2 |
| Notes | : | |

# ប្រទេសកម្ពុជាជាគំរូល្អក្នុងការផ្សះផ្សារជាតិ តែជាគំរូមិនល្អសំរាប់អំពើពុករលួយ

ប្រទេសសឹង្ហបុរីៈ នៅក្នុងអំឡុងពេលកិច្ចប្រជុំតុមូលអាស៊ី-អឺរ៉ុប (5thAsia-Europe Roundtable) លើកទីប្រាំស្តីពីការរក្សាសន្តិភាព តាមរយៈ ការស្ថាបនាឡើងវិញក្រោយពីសង្គ្រាម ដែលកិច្ចប្រជុំនេះ ធ្វើនៅប្រទេសសឹង្ហបុរី ហើយប្រទេសកម្ពុជាត្រូវបានប្រទេស ដែលទើបងើប ពីសង្គ្រាមដទៃទៀត យកជាគំរូ ក្នុងកិច្ចការផ្សះផ្សារជាតិ ។

នៅក្នុងកិច្ចប្រជុំតុមូលរយៈពេលបីថ្ងៃនោះ មានវាគ្មិន និងអ្នកអង្កេតការណ៍ជាច្រើនរូប បានចូលរួមផ្តល់អនុសាសន៍ល្អៗ ក្នុងការស្ថាបនា និងរក្សាអោយមានសន្តិភាពជានិរន្តក្នុងប្រទេស ដែលទើបងើបពីសង្គ្រាម ។ អ្នកចូលរួមទាំងនោះមកពីប្រទេសផ្សេងៗ លើកពិភពលោក ដែលក្នុងនោះដែរ ប្រទេសកម្ពុជា ក៏មានតំណាងរបស់ខ្លួនដើម្បីចូលរួមផ្តល់បទពិសោធន៍ ក្នុងនាមខ្លួនជារាមច្បងនៃប្រទេសមួយចំនួន ដែលទើបងើបពីសង្គ្រាមថ្មីថ្មោង ក្រោយប្រទេសកម្ពុជា ។

លោក មុនាវ៉ាលីហ្សាហ្សាយណាល (Munawar Liza Zainal) ដែលមានមុខងារលោកជា ចៅហ្វាយក្រុងសាបាង (Sabang) នៅ Gaeq (Aceh) ដែលជាប្រទេស ទើបងើបពីសង្គ្រាមប៉ុន្មានឆ្នាំថ្មីៗនេះ បានមានប្រសាសន៍ថា លោកនឹងយកប្រទេសកម្ពុជាជាគំរូក្នុងការផ្សះផ្សារ និង កសាងប្រទេសរបស់ឡើងវិញ ។

លោក មុនាវ៉ា (Munawar) បានកោតសរសើរប្រទេសកម្ពុជាថា "ប្រទេសកម្ពុជាមានភាពជោគជ័យក្នុងការផ្សះផ្សារជាតិឡើងវិញ ចំណែកឯអាឆេ (Aceh) មិនទាន់មាននៅឡើយ ។ ហើយខ្ញុំសង្ឃឹមថា នៅថ្ងៃអនាគតខាងមុខឆាប់ៗនេះ អាឆេ (Aceh) នឹង មានការផ្សះផ្សារជាតិប្រកបទៅដោយ ភាពជោគជ័យដូចប្រទេសកម្ពុជាដែរ ។"

លោកស្រី ហេឡេន ចាវិស (Helen Jarvis) ជាអ្នកតំណាងអោយប្រទេសកម្ពុជានៅក្នុងកិច្ចប្រជុំនោះ ហើយដែលសព្វថ្ងៃលោកស្រីមានមុខងារ

*តទៅទំព័រទី៣២*

| | | |
|---|---|---|
| Name of Media | : | Phnom Penh Post, Cambodia |
| Date of Article | : | 1 July 2007 |
| Author | : | Rith sam |
| Pages | : | 2/2 |
| Notes | : | |

*តមកពីទំព័រទី១២*

## ប្រទេសកម្ពុជា...

ជាប្រធានមុខងារសាធារណៈនៃអង្គជំនុំជំរះវិសាមញ្ញនៃតុលាការកម្ពុជា បានមានប្រសាសន៍ថា ប្រទេសកម្ពុជាអាចទុកបានថា ជាប្រទេសមាន សន្តិភាពបរិបូរណ៍ ដែលខុសពីប្រទេសដែលទើបងើបពីសង្គ្រាមដទៃផ្សេងទៀត ។ ដោយសារ ប្រទេសកម្ពុជាមានរៀបចំការបោះឆ្នោតបីអាណត្តិរួចហើយ ។

លោកស្រី ហេឡេន (Helen)បានរាបរាប់ អំពីដំណើរការណ៍ផ្សះផ្សារជាតិ ដែលប្រទេសកម្ពុជាធ្លាប់ ឆ្លងកាត់ក្រោយពីសង្គ្រាមរហូតដល់ការរៀបចំអោយមានដំណើរការណ៍កាត់ក្តីមេដឹកនាំ និងអ្នកទទួលខុសត្រូវចំបងនៅក្នុងរបបខ្មែរក្រហម ។

លោក លី ចុងសាន (Lee Chong San) សមាជិកក្រុមប្រឹក្សាភិបាលនៃអង្គការតម្លាភាពអន្តរជាតិ (Transparency International) ដែលមានវត្តមានផងដែរ នៅក្នុងកិច្ចប្រជុំតុមូលអាស៊ី-អឺរ៉ុបលើកទីប្រាំនោះ បានមានប្រសាសន៍ថា លោកសង្ឃឹមជឿជាក់ថា ប្រទេសកម្ពុជា នឹងមានការរីកចំរើនល្អតលាស់ មិនចាញ់ប្រទេសជិតខាងរបស់ខ្លួន នាពេលខាងមុខឆាប់ៗនេះ ប្រសិនបើប្រទេសនេះអាចកាត់បន្ថយអោយបាននូវអំពើពុករលួយ ។

លោកចុងសាន (Chong San) បានមានប្រសាសន៍ថា តាមរបាយការណ៍របស់ Transparency International កាលពីឆ្នាំ ២00៦ បានបង្ហាញថាប្រទេសកម្ពុជាជាប់ចំណាត់ថ្នាក់លេខ ១៥១ ខាងអំពើពុករលួយក្នុងចំណោម ១៦៣ ប្រទេស ( លំដាប់ថ្នាក់លេខ១ : ប្រទេសមានអំពើពុករលួយ តិចជាងគេបំផុត ហើយលំដាប់ថ្នាក់លេខ ១៦៣ : ប្រទេស ដែលមាន អំពើពុករលួយខ្លាំងជាង គេបំផុត ) ។

ប៉ុន្តែលោកបានមានប្រសាសន៍បន្ថែមទៀតថា អំពើពុករលួយនេះអាចត្រូវកាត់បន្ថយយ៉ាងលឿនបាន ទាល់តែមានការចូលរួមចំណែកពីប្រទេសផ្តល់ជំនួយក្នុងការស្រាវជ្រាវ និងតាមដានរកភាពមិនប្រក្រតីណាមួយនៃជំនួយរបស់ខ្លួន ។

នៅពេលទទួលបានរបាយការណ៍បន្ទាប់ពីធ្វើសវនកម្ម ច្បាស់លាស់ហើយ អ្នកផ្តល់ជំនួយគួរផ្សព្វផ្សាយរបាយការណ៍នោះ ជាសាធារណៈ ដោយធ្វើយ៉ាងណា ជំរុញអោយរដ្ឋាភិបាលដាក់ទណ្ឌកម្មទៅដល់អ្នកដែលប្រព្រឹត្តអំពើពុករលួយនោះ ។

សូមបញ្ជាក់ថា កិច្ចប្រជុំតុមូលអាស៊ី-អឺរ៉ុបលើកទីប្រាំនេះ មានការសហការណ៍ និង រៀបចំឡើងដោយមូលនិធិអាស៊ី-អឺរ៉ុប (Asia-Europe Foundation) និង (Friedrich Ebert Stiftung) ។

*ដោយ លោក មាន សំណាង*

| | | |
|---|---|---|
| Name of Media | : | Phnom Penh Post, Cambodia |
| Date of Article | : | 1 July 2007 |
| Author | : | Rith sam |
| Pages | : | 1/2 |
| Notes | : | Translation |

By Sam Rith

During the fifth Asia-Europe roundtable meeting on sustaining the peace through post conflict reconstruction on May 23-25 in Singapore, Cambodia was addressed as a lesson learn for other post conflict countries.

Some participants in the three days period meeting complimented Cambodia on having a successful reconciliation process after the conflict that would be taken as the examples by other post conflict countries, while others criticized Cambodia still has a serious problem of corruption—the meeting was co-organized by Asia Europe Foundation and Friedrich Ebert Stiftung that had 50 participants of different backgrounds including policy makers, academics, practitioners and civil society activists and donor organizations.

Munawar Liza Zainal, the major of Sabang City in Aceh and deputy Spokesperson of the former Free Aceh Movement, said he would like to take Cambodia as the example on reconciliation in Aceh.

"Cambodia has a very successful in the reconciliation, but not yet in Aceh," Munawar said. "We hope that in the near future, we will have a success reconciliation like Cambodia."

Helen Jarvis, chief of public affairs at the Extraordinary Chambers in the Courts of Cambodia [ECCC] who is representative of Cambodia, said at the roundtable discussion that Cambodia has a valuable experience for other post conflict countries to take as the lesson.

"We had integration of the former fighting component and element of reconciliation," Helen said.

She said even though Cambodia has already had three mandates of the government, for almost 15 years, it still has some aspects of post conflict situation, and she thought that the forthcoming trial would end the post conflict in Cambodia.

But Lee Chong San, board member of the international board of director of Transparency International, said Cambodia was placed 151 as corrupt country while East Timor placed 111 and Sierra Leone 142—Chong San said basing on Transparency International Corruption Perception Index in 2006.

| | | |
|---|---|---|
| Name of Media | : | Phnom Penh Post, Cambodia |
| Date of Article | : | 1 July 2007 |
| Author | : | Rith sam |
| Pages | : | 2/2 |
| Notes | : | Translation |

Chong San said Cambodia has low corruption comparing to Iraq that placed 160 and the Democratic Republic of Congo that placed 156 out of 163 countries.

"Of course [Cambodia] still has [corruption] issue," said Chong San. "As long as the government and [donor] remains working together and keep moving forward, I think in the future, Cambodia will be bright and much better than other countries."

Strict monitoring standards imposed by many international donors and implementing agencies can contribute towards mitigating corruption, but he said the concern is that a number of the donors are reluctant to denounce corruption.

"To contribute in eradicating the corruption, the donor should publicize after they audited and found out the corruption," Chong San said. "And make sure the person who committed corruption get penalized."

//